THE SCHOOL DISTRICT OF PHILADELPHIA

**OPERATIONS DIVISION**
440 North Broad Street, Suite 3226
Philadelphia, PA 19130

**Oz Hill**
Interim Deputy Superintendent of Operations

ថ្ងៃទី 11 ខែ តុលា ឆ្នាំ 2024

ជូនចំពោះ ក្រុមគ្រួសាររបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

យើងខ្ញុំសរសេរលិខិតនេះដើម្បីជម្រាបលោកអ្នកអំពីការដកចេញម្ហូបអាហារដែលអាចប៉ះពាល់ដល់កូនរបស់លោកអ្នក ដោយសារកូនរបស់លោកអ្នករៀននៅ ទីតាំង ថ្នាក់មុនមត្តេយ្យ ឬថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី 12 (Pre-K or K-12 site) ដែលអាចរងផលប៉ះពាល់។

ថ្ងៃនេះ ក្រុមហ៊ុនធ្វើម្ហូបអាហារឈ្មោះ **Whitsons Culinary Group** ដែលជាផ្នែកនៃកម្មវិធីម្ហូបអាហារ បានផ្តល់ដំណឹងដល់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាថា ផលិតផលសាច់មាន់មួយចំនួនដែលបានផ្តល់ឱ្យសិស្សថ្នាក់មុនមត្តេយ្យ ឬសាលារបស់យើង កំពុងស្ថិតនៅក្រោមការដកចេញទូទាំងប្រទេស ដោយសារអាហារទាំងនេះអាចមានការចម្លងរោគដោយ មេរោគនៅក្នុងអាហារដែលមានឈ្មោះថា Listeria monocytogenes។

បញ្ជីឈ្មោះទីតាំងថ្នាក់មុនមត្តេយ្យ និងសាលា ដែលរងផលប៉ះពាល់មាននៅទីនេះ៖
https://docs.google.com/spreadsheets/d/14KxpBKtf5u2wp8oPuoHsdtIMHhfa7wzyqlvKVbITWjw/edit?usp=sharing

ទីតាំង ឈ្មោះអាហារ និងកាលបរិច្ឆេទដែលពាក់ព័ន្ធ នៅពេលដែលពួកគេត្រូវបានផ្តល់អាហារ មានដូចខាងក្រោមនេះ៖

- ថ្នាក់មុនមត្តេយ្យ៖ Chicken & Broccoli Alfredo Penne (បានផ្តល់អាហារនៅថ្ងៃទី 8 ខែ តុលា)
- កុមារ ថ្នាក់មុនមត្តេយ្យ ដែលមានអាហារជំនួសដោយសារប្រតិកម្មនឹងអាហារអ្វីមួយ៖
  Chicken Strips Honey Mustard Green Bean (បានផ្តល់អាហារនៅចន្លោះថ្ងៃទី 4 ដល់ថ្ងៃទី 10 ខែ តុលា) និង Chicken Caribbean Pineapple Sauce Rice Carrots (បានផ្តល់អាហារនៅចន្លោះថ្ងៃទី 4 ដល់ថ្ងៃទី 10 ខែ តុលា)
- ទីតាំង ថ្នាក់មត្តេយ្យ ដល់ទី 12៖
  Chicken w/BBQ Sauce Rice Baked Beans (បានផ្តល់អាហារនៅថ្ងៃទី 23 ខែ កញ្ញា ឆ្នាំ 2024)

សំណាងល្អ យោងតាម ក្រសួងផ្នែកត្រួតពិនិត្យ និងសុវត្ថិភាពចំណីអាហារ (FSIS) របស់ USDA មិនមានរបាយការណ៍ដែលបញ្ជាក់ថាមានប្រតិកម្មមិនល្អដោយសារតែការទទួលទានអាហារទាំងអស់នោះឡើយ។ ដើម្បីជ្រាបព័ត៌មានបន្ថែមទាក់ទងនឹងការដកចេញអាហារទូទាំងប្រទេសនេះ សូមមើលគេហទំព័រ៖

THE SCHOOL DISTRICT OF PHILADELPHIA

**OPERATIONS DIVISION**
440 North Broad Street, Suite 3226
Philadelphia, PA 19130

**Oz Hill**
Interim Deputy Superintendent of Operations

https://www.fsis.usda.gov/recalls-alerts/brucepac-recalls-ready-eat-meat-and-poultry-products-due-possible-listeria

ក្រសួងផ្នែកសេវាកម្មម្ហូបអាហាររបស់ក្រសួងអប់រំកំពុងដកចេញម្ហូបអាហារដែលនៅសល់ទាំងអស់ចេញពីសេវាកម្មម្ហូបអាហារសាលាទាំងអស់។ ទៅថ្ងៃមុខ កូនរបស់លោកអ្នកនឹងមិនត្រូវបានផ្តល់ម្ហូបអាហារនេះទៀតទេ។ ប្រសិនបើលោកអ្នកមានសំណួរអ្វី សូមទាក់ទងតាមអ៊ីមែល recallnotification101024@philasd.org ឬទូរស័ព្ទទៅលេខ 215-400-5600។

សូមអរគុណចំពោះការយកចិត្តទុកដាក់របស់លោកអ្នកដល់បញ្ហាដ៏សំខាន់នេះ។ អាទិភាពចម្បងរបស់យើងគឺសុខភាព និងសុវត្ថិភាពរបស់សិស្សានុសិស្សរបស់យើង ហើយយើងខ្ញុំប្តេជ្ញាផ្តល់ម្ហូបអាហារដែលមានសុវត្ថិភាព និងមានជីវជាតិ។ នរណាម្នាក់ដែលមានការព្រួយបារម្ភអំពីជំងឺត្រូវទាក់ទងគ្រូពេទ្យកុមារ ឬអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់កូនលោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ

Oz Hill
អគ្គនាយករងស្តីទី ផ្នែកប្រតិបត្តិការណ៍